**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**សាលាខេត្តកណ្តាល**
លេខ:..០៣៥..ស.សរ.

កណ្តាល. ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០

# សេចក្តីសំរេច

## ស្តីពីការធ្វើប្រតិភូកម្មលើការងារនីត្យានុកូលកម្ម លើឯកសារថតចម្លងផ្សេងៗក្នុងក្រុងតាខ្មៅអោយទៅ ការិយាល័យច្រកចេញ-ចូលតែមួយរបស់ក្រុងតាខ្មៅ

## អភិបាលខេត្តកណ្តាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៥៩ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល

-យោងសេចក្តីសម្រេចលេខ ១២.សសរ. ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យច្រកចេញ-ចូលតែមួយនៅថ្នាក់ក្រុង-ស្រុក.ខណ្ឌ ។

-យោងលិខិតលេខ ៦៤៣ សជណ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ. ស្តីពីការធ្វើប្រតិភូកម្មលើការងារនីត្យានុកូលកម្មលើឯកសារថតចម្លងផ្សេងៗ ទៅអោយក្រុង-ស្រុក គោលដៅនៃគម្រោងការិយាល័យច្រកចេញ-ចូលតែមួយ ។

## សំរេច

**ប្រការ ១ :** ត្រូវបានប្រគល់អោយការិយាល័យច្រកចេញ-ចូលតែមួយ នៃក្រុងតាខ្មៅធ្វើនិត្យានុកូលកម្មលើឯកសារថតចម្លងផ្សេងៗ ដែលស្ថិតនៅក្នុងក្រុងតាខ្មៅ ដូចមានបញ្ជីឯកសារជូនភ្ជាប់ ។

**ប្រការ ២ :** នាយករដ្ឋបាលសាលាខេត្ត សាលាក្រុងតាខ្មៅ.ការិយាល័យច្រកចេញ-ចូលតែមួយនៃក្រុងតាខ្មៅ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អភិបាលខេត្ត**

**ចម្លងជូន**
-ក្រសួងមហាផ្ទៃ
(ដើម្បីជូនជ្រាប)
-មន្ទីរអង្គភាពជុំវិញខេត្ត
(ដើម្បីជ្រាប)
-ឯកសារ- កាលប្បវត្តិ

# បញ្ជីឯកសារដែលត្រូវធ្វើប្រតិភូកម្មលើឯកសារថតចម្លង

| ល.រ | ប្រភេទនីត្យានុកូលកម្មឯកសារថតចម្លង |
|---|---|
| ១ | វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាកំរិត១ |
| ២ | វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិ |
| ៣ | វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាទុតិយភូមិ |
| ៤ | វិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី១២ |
| ៥ | លិខិតបញ្ជាក់លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាកំរិត១ |
| ៦ | សញ្ញាបត្រមធ្យមសិក្សាកំរិត២ ( បំពេញវិជ្ជា) |
| ៧ | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ |
| ៨ | ព្រឹត្តិបត្រលទ្ធផលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ |
| ៩ | ព្រឹត្តបត្រពិន្ទុ |
| ១០ | ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកំរិត២ចំណេះដឹងទូទៅ |

# តារាងកំរៃសេវានីត្យានុកូលកម្ម

| ល.រ | រាយមុខសេវាកម្ម | កំរៃសេវាកម្ម | | | |
|---|---|---|---|---|---|
| | | តម្លៃតែមប្រិ៍ | តម្លៃសេវា | ទឹកប្រាក់ | ចំនួនសន្លឹក |
| ១ | ព្រឹត្តិបត្រពិន្ទុ ឬ ព្រឹត្តិបត្រលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | ៣០០៛ | ៤០០៛ | ៧០០៛ | ១សន្លឹក |
| ២ | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ.វិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី១២ | ៣០០៛ | ៤០០៛ | ៧០០៛ | ១សន្លឹក |
| ៣ | ប័ណ្ណប៉ាតង់. វិញ្ញាបនប័ត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម-សេវាកម្ម | ៥០០៛ | ៧០០៛ | ១២០០៛ | ១សន្លឹក |
| ៤ | វិញ្ញាបនប័ត្រផ្សេងៗ | ៣០០៛ | ៤០០៛ | ៧០០៛ | ១សន្លឹក |
| ៥ | អត្តសញ្ញាណប័ណ្ណ.សៀវភៅស្នាក់នៅ.សៀវភៅគ្រួសារ | ៣០០៛ | ៤០០៛ | ៧០០៛ | ១សន្លឹក |
| ៦ | ប្លង់សំណង់.ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ | ៥០០៛ | ១០០០៛ | ១៥០០៛ | ១សន្លឹក |
| ៧ | លិខិតផ្សេងៗ ចេញដោយមេឃុំ | ៣០០៛ | ៤០០៛ | ៧០០៛ | ១សន្លឹក |
| ៨ | លិខិតបញ្ជាក់ ឬ លិខិតអនុញ្ញាតផ្សេងៗ ចេញដោយមន្ទីរជុំវិញខេត្ត | ៣០០៛ | ៤០០៛ | ៧០០៛ | ១សន្លឹក |
| ៩ | ប័ណ្ណសំគាល់យានយន្ត | ៣០០៛ | ៧០០៛ | ១០០០៛ | ១សន្លឹក |